កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមរដ្ឋប្បវេណីលេខ ៩៩៤(ខ)
ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩
សំណុំរឿងរដ្ឋប្បវេណីលេខ ៥០៤
ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោងប្រាំបួនព្រឹក នៅសាលសវនាការទី ៥ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៥០៤ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ ដោយមានសមាសភាព:

<u>ចៅក្រមជំនុំជម្រះ</u>

លោក រស់ សាម៉ីឌី ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

<u>ក្រឡាបញ្ជី</u>

លោក ចៅ ឃាន ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

រវាងដើមចោទធនាគារ ជ មានមេធាវីតំណាងដោយអាណត្តិ លោកស៊ីវ វណ្ណារិទ្ធ លោកលី សំបូរ៉ម្ម លោកកាត ១ និងសហចុងចម្លើយឈ្មោះ ច១ ភេទប្រុស កើតនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៥៧ និងប្រពន្ធឈ្មោះ ច២ កើតនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៥៨ និងកូនឈ្មោះ ច៣ ភេទប្រុស កើតថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៨៨ មានទីលំនៅបច្ចុប្បន្ន:ផ្ទះលេខ រាជធានីភ្នំពេញ មានមេធាវីតំណាងដោយអាណត្តលោកស្បែន សុលរយោ ។

<u>I.អង្គហេតុនិងចំណុចវិវាទ</u>

<u>ក-ការទាមទាររបស់ដើមចោទ</u>

១-ប្រាក់ដើមចំនួន**៤៣៦.៥៥៦,៥៩$**(បួនរយសាមសិបប្រាំមួយពាន់បួន រយហាសិបប្រាំមួយដុល្លារ និងសែសិបប្រាំបួនសេន) ។

២-ការប្រាក់និងប្រាក់ពិន័យចំនួន**១៣១៩២,៤១$** (មួយម៉ឺនបីពាន់មួយរយកៅសិបពីរដុល្លារ និងសែសិបមួយសេន) គិតថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ ។

៣-ការប្រាក់កំចីហួសកាលកំណត់ចំនួន**១៣,៣៥%** (ដប់បីក្បៀសសាមសិបប្រាំភាគរយ) ក្នុង១ឆ្នាំ គិតថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ រហូតដល់សងគ្រប់ចំនួន ។

៤-សំណងជម្ងឺចិត្តចំនួន**៥0000$**(ប្រាំម៉ឺនដុល្លារអាមេរិក) ។

៥-សុំបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភាគ ដើម្បីទទួលបានការសងតាមការសងតាមលំដាប់អត្ថិភាព ។

៦-សុំប្រកាសសាលក្រមអនុវត្តជាបណ្តោះអាសន្ន ។

៧-ប្រាក់ប្រដាប់ក្តីជាបន្ទុកភាគីសហចុងចម្លើយ ។

<u>ខ-ការពន្យល់ត្រួសៗពីដំណើរឿងក្តី</u>

ដើមចោទបានសុំឲ្យតុលាការចេញសាលក្រមតាមការទាមទារក្នុងចំណុច(ក)ដោយហេតុថា:កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ ធនាគារ ជ សាខាភ្នំពេញ បានចុះកិច្ចសន្យាផ្តល់ឥណទានរយៈពេលវែងលេខ ចុះថ្ងៃទ០ ខែមីនា ឆ្នាំ២០១៨ ទៅឲ្យសហចុងចម្លើយក្នុងរយៈពេល១២០ខែ ចំនួន**៤៥0000$**(បួនរយហាសិបពាន់ដុល្លារអាមេរិក) ហើយដើម្បីធានាការអនុវត្តកាតព្វកិច្ចប្រាក់ខ្ចីនេះសហចុងចម្លើយ បានយកកម្មសិទ្ធិជាទ្រព្យរបស់ខ្លួនដែលមានក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុ និងទ្រព្យផ្សេងៗដែលនៅជាប់និងអចលនវត្ថុលេខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ មកដាក់បញ្ចាំជាមួយធនាគារ ។ ពេលវេលាកំណត់សងប្រាក់ដើមមកដល់ភាគីសហចុងចម្លើយនៅតែមិនព្រមធ្វើការ

កំណត់សំគាល់: សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជា សាលក្រមគម្រូទេ

ទូរទាត់សងប្រាក់មកធនាគារនោះទេ ព្រមទាំងខកខានបង់ប្រាក់ដើម និងការប្រាក់ជូនមកធនាគារចាប់តាំងពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន ដែលជាហេតុធ្វើឲ្យប៉ះពាល់ផលប្រយោជន៍ធនាគារយ៉ាងធ្ងន់ធ្ងរនិងនិរន្តភាពរបស់ធនាគារ នេះចាត់ទុកថាជាការបំពានកាតព្វកិច្ចរបស់ភាគីអ្នកខ្ចីចំពោះធនាគារ ដែលនាំឲ្យធនាគារអាចចាត់វិធានការតាមផ្លូវច្បាប់ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួនឲ្យទាន់ពេលវេលា ។

<u>គ-អង្គហេតុដែលអះអាងដោយភាគីដើមចោទ</u>

-លោកលី សំបូរិទ្ធិ ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីដើមចោទធនាគារ ជ

បានថ្លែងការណ៍ថា:កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ ធនាគារ ជ

សាខាភ្នំពេញរបស់កូនក្តីខ្លួនបានចុះកិច្ចសន្យាផ្តល់ឥណទានរយៈពេលវែងលេខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ទៅឲ្យសហធុងចម្លើយក្នុងរយៈពេល១២០ខែ ចំនួន**៤៥0000$**(បួនរយហាសិបពាន់ដុល្លារអាមេរិក) ហើយដើម្បីធានាការអនុវត្តកាតព្វកិច្ចប្រាក់ខ្ចីនេះ សហធុងចម្លើយបានយកកម្មសិទ្ធិជាទ្រព្យរបស់ខ្លួនដែលមានក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុនិងទ្រព្យផ្សេងៗដែលនៅជាប់និងអចលនវត្ថុលេខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ មកដាក់បញ្ចាំជាមួយធនាគារ ។ ពេលវេលាកំណត់សងប្រាក់ដើមមកដល់ភាគីសហធុងចម្លើយនៅតែមិនព្រមធ្វើការទូរទាត់សងប្រាក់មកធនាគារនោះទេព្រមទាំងខកខានបង់ប្រាក់ដើមនិងការប្រាក់ជូនមកធនាគារចាប់តាំងពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន ដែលជាហេតុធ្វើឲ្យប៉ះពាល់ផលប្រយោជន៍ធនាគារយ៉ាងធ្ងន់ធ្ងរនិងនិរន្តភាពរបស់ធនាគារ នេះចាត់ទុកថាជាការបំពានកាតព្វកិច្ចរបស់ភាគីអ្នកខ្ចីចំពោះធនាគារ ដែលអាំឲ្យធនាគារអាចចាត់វិធានការតាមផ្លូវច្បាប់ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួនឲ្យទាន់ពេលវេលា ដូច្នេះសំណូមសុំឲ្យតុលាការចេញសាលក្រមសម្រេចតាមការប្តឹងសុំខាងលើដោយក្តីអនុគ្រោះ ។

<u>ឃ-អង្គហេតុដែលអះអាងដោយភាគីចុងចម្លើយ</u>

-លោកសៀន ស៊ីលវីយោ ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីសហចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា: កូនក្តីខ្លួនទទួលស្គាល់ថាពិតជាបានចុះកិច្ចសន្យាខ្ចីប្រាក់ធនាគារចំនួន**៤៥0000$**(បួនរយហាសិបពាន់ដុល្លារអាមេរិក) ឯការទាមទារប្រាក់ចំនួន**៤៣៦.៤៥៦,៤៩$** (បួនរយសាមសិបប្រាំមួយពាន់បួនរយហាសិបប្រាំមួយដុល្លារនិងសែសិបប្រាំបួនសេន) ចាំខ្លួនផ្តល់ឯកសារនិងធ្វើសេចក្តីថ្លែងការណ៍ជូនតុលាការចំណែកការប្តឹងទាមទារសំណងផ្សេងៗកូនក្តីខ្លួនសុំបដិសេធចោល ។

<u>ង-ចំណុចវិវាទនិងចំណុចគ្មានវិវាទ</u>

-ចំណុចវិវាទ:ចុងចម្លើយមិនឯកភាពលើការប្រាក់ ប្រាក់ពិន័យ ប្រាក់ជម្ងឺចិត្ត និងអនុវត្តជាបណ្តោះអាសន្ន

-ចំណុចគ្មានវិវាទ:ចុងចម្លើយឯកភាពលើប្រាក់ដើម ។

<u>II.ការពិនិត្យភស្តុតាង</u>

១-ភស្តុតាងជាឯកសាររបស់ភាគីដើមចោទ

-កិច្ចសន្យាផ្តល់ឥណទានរយៈពេលវែងលេខ ចុះថ្ងៃទី៣០ខែមីនា ឆ្នាំ២០១៨

-កិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុនិងទ្រព្យផ្សេងៗដែលនៅជាប់និងអចលនវត្ថុ លេខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ។

<u>សំអាងហេតុ</u>

១-តាមលទ្ធផលសាកសួរនិងពិនិត្យភស្តុតាងនៅនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា:កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ ធនាគារ ជ សាខាភ្នំពេញ បានចុះកិច្ចសន្យាផ្តល់ឥណទានរយៈពេលវែងលេខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ទៅឲ្យសហធុងចម្លើយក្នុងរយៈពេល១២០ខែ ចំនួន**៤៥0000$**(បួនរយហាសិបពាន់ដុល្លារអាមេរិក) ហើយដើម្បីធានាការអនុវត្តកាតព្វកិច្ចប្រាក់ខ្ចីនេះ សហធុងចម្លើយបានយកកម្មសិទ្ធិជាទ្រព្យរបស់ខ្លួនដែលមានក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុ និងទ្រព្យផ្សេងៗដែលនៅជាប់និងអចលនវត្ថុលេខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ មកដាក់បញ្ចាំជាមួយធនាគារ ។ ពេលវេលាកំណត់សងប្រាក់ដើមមកដល់ភាគីសហធុងចម្លើយនៅតែមិនព្រមធ្វើការទូរទាត់សងប្រាក់មកធនាគារនោះទេ ព្រមទាំងខកខានបង់ប្រាក់ដើមនិងការប្រាក់ជូនមកធនាគារចាប់តាំងពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន ដែលជាហេតុធ្វើឲ្យប៉ះពាល់ផលប្រយោជន៍ធនាគារយ៉ាងធ្ងន់ធ្ងរនិងនិរន្តភាពរបស់ធនាគារ នេះចាត់ទុកថាជាការបំពានកាតព្វកិច្ចរបស់ភាគីអ្នកខ្ចីចំពោះធនាគារដែលនាំឲ្យធនាគារអាចចាត់វិធានការតាមផ្លូវច្បាប់ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួនឲ្យទាន់ពេលវេលា ។

២-មេធាវីតំណាងដោយអាណត្តិសហធុងចម្លើយបានទទួលស្គាល់ថាកូនក្តីខ្លួនពិតជាចុះកិច្ចសន្យាខ្ចីប្រាក់ពីធនាគារចំនួន**៤៥0000$**(បួនរយហាសិបពាន់ដុល្លារអាមេរិក) ឯការទាមទារប្រាក់ចំនួន**៤៣៦.៤៥៦,៤៩$** (បួនរយសាមសិបប្រាំមួយពាន់បួនរយហាសិបប្រាំមួយដុល្លារ និងសែសិបប្រាំបួនសេន) ខ្លួនពុំច្បាស់ទេចាំកូនក្តីផ្តល់ឯកសារជូនតុលាការ ។

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

៣-ភាគីដើមចោទបានអះអាងថាសហធុងចម្លើយឈ្មោះ **ច១ , ច២ , ច៣** បានចុះកិច្ចសន្យាខ្ចីផ្តល់ឥណទានរយៈពេលវែង និងការបង្កើតហ៊ីប៉ូតែកជាមួយធនាគា **ដ** មានចំនួនទឹកប្រាក់ចំនួន**៥៥0000$**(បួនរយហាសិបពាន់ដុល្លារអាមេរិក) ខ្ចីក្នុងរយៈពេល១២០ខែ ហើយគិតការប្រាក់៨.៩%ក្នុងមួយឆ្នាំ និងសំណងការខូចខាតចំនួន២៥% ក្នុងមួយឆ្នាំ ។ ដើម្បីធានាអនុវត្តកាតព្វកិច្ចប្រាក់ខ្ចីនេះសហធុងចម្លើយឈ្មោះ **ច១ , ច២** និងឈ្មោះ **ច.៣** បានយកកម្មសិទ្ធិជាទ្រព្យសម្បត្តិរបស់ខ្លួនដែលមានក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុនិងទ្រព្យផ្សេងៗដែលនៅជាប់និងអចលនវត្ថុ **លេខ** ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ។ ចាប់តាំងពីថ្ងៃទីដែលមានក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុនិងទ្រព្យផ្សេងៗដែលនៅជាប់និងអចលនវត្ថុ**លេខ** ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ រហូតមកដល់ពេលនេះសហធុងចម្លើយខកខានបង់ការប្រាក់និងប្រាក់ដើមមកឲ្យធនាគារ ។

៤-ភាគីធុងចម្លើយពុំបានបំពេញកាតព្វកិច្ចបង់ការប្រាក់ និងប្រាក់ដើមឲ្យដល់ធនាគារតាមការកំណត់ដូចមានចែងក្នុងកិច្ចសន្យាចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ការមិនបំពេញកាតព្វកិច្ចរបស់សហធុងចម្លើយគឺជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។

៥-ដើមចោទទាមទារការប្រាក់គិតពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ ដែលមានចំនួន**១៣១៩២,៤១$** (មួយម៉ឺនបីពាន់មួយរយកៅសិបពីរដុល្លារនិងសែសិបមួយសេន) ដោយបានគណនាតាមអត្រាការប្រាក់៨.៩%ក្នុងមួយឆ្នាំ និងអត្រាការប្រាក់ហួសកាលកំណត់ស្មើនិង១៣.៣៥%(ដប់បីក្បៀសសាមសិបប្រាំភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមគិតពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន ។

៦-ដើមចោទទាមទារសំណងជម្ងឺចិត្តចំនួន**៥0000$**(ប្រាំម៉ឺនដុល្លារអាមេរិក) គឺមានលក្ខណៈត្រឹមត្រូវ ពីព្រោះដើមចោទខាតបង់ពេលវេលាក្នុងនីតិវិធីតុលាការ ដូច្នេះគប្បីតុលាការពិចារណា ។

៧-ពេលគូភាគីបង្កើតកិច្ចសន្យាផ្តល់ឥណទានរយៈពេលវែង គូភាគីបានចុះកិច្ចសន្យាខ្ចីប្រាក់និងការបង្កើតហ៊ីប៉ូតែក ហើយគូភាគីបានចុះកិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុនិងទ្រព្យផ្សេងៗទៀតដែលនៅជាប់នឹងអចលនវត្ថុ**លេខ** ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ គឺគូភាគីបានបង្កើតហ៊ីប៉ូតែកស្របតាមមាត្រា៨៤៤ នៃក្រមរដ្ឋប្បវេណី ។ បន្ទាប់មកភាគីដើមចោទបានដាក់ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកទៅលោកប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានីភ្នំពេញតាមនីតិវិធី ។ ដូច្នេះគប្បីតុលាការទទួលស្គាល់ពីអត្ថិភាពនៃសិទ្ធិប្រាតិភោគរបស់ដើមចោទលើអចលនទ្រព្យរបស់សហធុងចម្លើយដែលបានដាក់ធានាលើបំណុល តាមមាត្រា៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៨-តាមអង្គហេតុខាងលើបានបង្ហាញថាធុងចម្លើយបានគេចវេសពីកាតព្វកិច្ចសងបំណុល ដើម្បីជៀសវាងការខាតប្រយោជន៍របស់ភាគីដើមចោទបន្តទៀត គប្បីតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើម ។

៩-ចំពោះប្រាក់ប្រដាប់ក្តី គប្បីដាក់បន្ទុកលើភាគីធុងចម្លើយ យោងតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

<u>សេចក្តីសម្រេចបញ្ជប់</u>

១.បង្គាប់ឲ្យសហធុងចម្លើយឈ្មោ **ច១ , ច២** និងឈ្មោះ **ច៣** សងប្រាក់មកដើមចោទធនាគារ **ដ** ដែលមានលោក **ឥជ** ជាតំណាងនូវទឹកប្រាក់ដូចខាងក្រោម:

ក/.ប្រាក់ដើមចំនួន**៤៣៦.៤៥៦,៤៩$**(បួនរយសាមសិបប្រាំមួយពាន់បួន រយហាសិបប្រាំមួយដុល្លារ និងសែសិបប្រាំបួនសេន) ។

ខ/.ការប្រាក់និងប្រាក់ពិន័យចំនួន**១៣១៩២,៤១$** (មួយម៉ឺនបីពាន់មួយរយកៅសិបពីរដុល្លារ និងសែសិបមួយសេន) គិតថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ ។

គ/.ការប្រាក់ចំហួសកាលកំណត់ចំនួន**១៣,៣៥%** (ដប់បីក្បៀសសាមសិបប្រាំភាគរយ) ក្នុង១ឆ្នាំ គិតថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ រហូតដល់សងគ្រប់ចំនួន ។

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

២.បង្គាប់ឲ្យសហឈ្មោះ **ច ១ , ច ២** និងឈ្មោះ **ច ៣** សងប្រាក់ជម្ងឺចិត្ត ចំនួន**៤0.000.000$** (សែសិបលានរៀល) ឲ្យទៅដើមចោទធនាគារ **ជ** ការទាមទារលើសពីនេះត្រូវច្រានចោល ។

៣.ដើមចោទមានអត្ថិភាពនៃសិទ្ធិប្រាតិភាគលើអចលនទ្រព្យរបស់សហចុងចម្លើយដែលដាក់ធានាបំណុល

៤-សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានលើចំណុច**១(ក)** ។

៥-សហចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃ**ទី១៧ ខែកក្កដា ឆ្នាំ២០១៩** និងប្រកាសជាសាធារណៈនៅថ្ងៃទី**០៦ ខែសីហា ឆ្នាំ២០១៩** ចំពោះមុខមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទនិងចំពោះមុខមេធាវីតំណាងដោយអាណត្តិឲ្យសហចុងចម្លើយ ។

ចៅក្រម

ហត្ថលេខានិងត្រា

រស់ សាម៉ីឌី

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃអង្គារ ៦កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពស២៥៦៣

ធ្វើនៅភ្នំពេញ ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩

ក្រឡាបញ្ជី

ជា ឃាន

បានឃើញ

ចៅក្រម

រស់_សាម៉ីឌី